# ស្តីពីការចាត់ចែងថ្មីពាក់ព័ន្ធនឹងសុពលភាពនៃលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ

ថ្ងៃទី 5 ខែកក្កដា ឆ្នាំ2021
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន
Immigration Services Agency of Japan

## គោលការណ៍ចាត់ចែង

- ជាការគិតគូរដល់ជនបរទេសដែលការចូលប្រទេសជប៉ុនរបស់គេត្រូវបានពន្យារដោយសារផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ១៩ ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុនបានចាត់វិធានការពិសេសដើម្បីបន្តសុពលភាពនៃលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ (ចាប់ពីពេលនេះតទៅហៅថា"លិខិតបញ្ជាក់") ចាំបាច់សម្រាប់នីតិវិធីអន្តោប្រវេសន៍ (ខាងក្រោមហៅថា "ការចាត់ចែងរហូតដល់បច្ចុប្បន្ន")។
- យោងលើស្ថានភាពបច្ចុប្បន្ន ដែលការរាលដាលនៃជំងឺកូវីដ១៩ នៅតែប៉ះពាល់ដល់នីតិវិធីអន្តោប្រវេសន៍ **ទីភ្នាក់ងារនឹងចាត់វិធានការដើម្បីបន្តសុពលភាពនៃលិខិតបញ្ជាក់** (ខាងក្រោមហៅថា "ការចាត់ចែងថ្មី")។

***លិខិតបញ្ជាក់ គឺដើម្បីបញ្ជាក់ភាពសមស្របនៃលក្ខខណ្ឌក្នុងការចូលប្រទេសជប៉ុននៅពេលដែលវាត្រូវបានចេញ។ ការពន្យារកម្លងពេលសុពលភាពវែងពេក អាចធ្វើអោយអត្រានៃភាពខុសគ្នានៃកាលៈទេសៈនៅពេលចូលប្រទេសជប៉ុន និងពេលដែលលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅត្រូវបានចេញកើនឡើង។ ហេតុដូច្នេះហើយ សុពលភាពនៃលិខិតបញ្ជាក់នឹងមិនត្រូវបានបន្តទៀតទេក្រោយពេលហួសកម្លងពេលផុតសុពលភាពដូចខាងក្រោម។ ប៉ុន្តែចំពោះពាក្យសុំលិខិតបញ្ជាក់ដែលត្រូវបានដាក់ចាប់ពីថ្ងៃទី31 ខែកក្កដា ឆ្នាំ2022 និងមុនកាលបរិច្ឆេទកំណត់ដោយទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន ដែលគ្មានខ្លឹមសារប្រែប្រួលចាប់តាំងពីពេលដាក់ពាក្យលើកមុន នោះជាគោលការណ៍ លិខិតបញ្ជាក់ថ្មីបន្ទាន់មួយនឹងត្រូវបានចេញអោយ ក្រោយអ្នកស្នើសុំបានដាក់ជូននូវ (1)លិខិតបញ្ជាក់ដែលត្រូវបានចេញលើកមុន(ឯកសារដើម ឬថតចម្លង) និង (2)លិខិតបញ្ជាក់មូលហេតុដែលធ្វើឡើងដោយស្ថាប័នទទួល ។ល។ ព័ត៌មានលំអិត សូមមើលកន្លែងនេះ។**

| ការចាត់ចែងរហូតដល់បច្ចុប្បន្ន | ការចាត់ចែងថ្មី |
| --- | --- |
| (1) លក្ខណៈសម្បត្តិស្នាក់នៅដែលជាមុខសញ្ញា<br>លក្ខណៈសម្បត្តិស្នាក់នៅទាំងអស់ដែលជាមុខសញ្ញានៃលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ | (1) លក្ខណៈសម្បត្តិស្នាក់នៅដែលជាមុខសញ្ញា<br>លក្ខណៈសម្បត្តិស្នាក់នៅទាំងអស់ដែលជាមុខសញ្ញានៃលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ |
| (2) តំបន់ដែលជាមុខសញ្ញា<br>គ្រប់ប្រទេសនិងតំបន់ទាំងអស់ | (2) តំបន់ដែលជាមុខសញ្ញា<br>គ្រប់ប្រទេសនិងតំបន់ទាំងអស់ |
| (3) លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលជាមុខសញ្ញា<br>**លិខិតដែលត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី1 តុលា 2019 តទៅ** | (3) លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលជាមុខសញ្ញា<br>**លិខិតដែលត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី1 មករា 2020 តទៅ** |
| (4) កម្លុងពេលដែលចាត់ទុកថា មានសុពលភាព<br>• លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានធ្វើឡើងពីថ្ងៃទី1 តុលា ដល់ ថ្ងៃទី 31 ធ្នូ 2019<br>→ **ដល់ថ្ងៃទី30 មេសា 2021**<br>• លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានធ្វើឡើងពីថ្ងៃទី1 មករា 2020 ដល់ ថ្ងៃទី 30 មករា 2021<br>→ **ដល់ថ្ងៃទី31 កក្កដា 2021**<br>• លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី31 មករា 2021 តទៅ<br>→ **មានសុពលភាព "6ខែ" គិតពីថ្ងៃដែលបានធ្វើ** | (4) កម្លុងពេលដែលចាត់ទុកថា មានសុពលភាព<br>• **លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានធ្វើឡើងពីថ្ងៃទី1 មករា 2020 ដល់ថ្ងៃទី 31 កក្កដា 2021**<br>→ **ដល់ថ្ងៃទី31 មករា 2022**<br>• **លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅដែលត្រូវបានធ្វើឡើងពីថ្ងៃទី1 សីហា 2021 ដល់ ថ្ងៃទី 31 មករា 2022**<br>→ **មានសុពលភាព "6ខែ" គិតពីថ្ងៃដែលបានធ្វើ** |
| (5) ល័ក្ខខ័ណ្ឌចាត់ទុកថាមានសុពលភាព<br>ករណីដែលពេលដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតឬកុងស៊ុលជប៉ុននៅក្រៅប្រទេស នៅក្នុងលិខិតដែលបានដាក់នោះមានបញ្ជាក់ថា ស្ថាប័នទទួល ជាអាទិ៍ "នៅតែអាចបន្តទទួលជនបរទេសបានតាមខ្លឹមសារនៃសកម្មភាពដែលមានចែងនៅពេលដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ"។ | (5) ល័ក្ខខ័ណ្ឌចាត់ទុកថាមានសុពលភាព<br>ករណីដែលពេលដាក់ពាក្យសុំទិដ្ឋាការនៅស្ថានទូតឬកុងស៊ុលជប៉ុននៅក្រៅប្រទេស នៅក្នុងលិខិតដែលបានដាក់នោះមានបញ្ជាក់ថា ស្ថាប័នទទួល ជាអាទិ៍ "នៅតែអាចបន្តទទួលជនបរទេសបានតាមខ្លឹមសារនៃសកម្មភាពដែលមានចែងនៅពេលដាក់ពាក្យសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ"។<br>ទម្រង់ឧបសម្ព័ន្ធ<សម្រាប់លក្ខណៈសម្បត្តិស្នាក់ក្នុងតារាង1 នៃឧបសម្ព័ន្ធ (ឧ:វិទ្យាសាស្ត្រ-ចំណេះដឹងអំពីមនុស្សសាស្ត្រ-ការងារអន្តរជាតិ/និស្សិត ។ល។)><br>ទម្រង់ឧបសម្ព័ន្ធ<សម្រាប់លក្ខណៈសម្បត្តិស្នាក់ក្នុងតារាង2 នៃឧបសម្ព័ន្ធ (ឧ: សហព័ទ្ធឬកូនរបស់ជនជាតិជប៉ុន អ្នកស្នាក់នៅជាប់លាប់ ។ល។)><br>*សូមដាក់ជូននូវឯកសារខាងលើម្តងទៀត ក្នុងករណីដែលរយៈពេល 3ខែបានកន្លងផុតទៅ រាប់ចាប់ពីពេលដាក់ពាក្យសុំទិដ្ឋាការ។ |